**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១១៤...អនក្រ.បក

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដឹកនាំការងារសរសេររបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ជូនអង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.)

## សម្រេច

**ប្រការ១.-** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដឹកនាំការងារសរសេររបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាជូនអង្គការសហប្រជាជាតិ ដែលមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម កែវ រ៉េមី | ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម អ៊ុច បូរិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣. | ឯកឧត្តម ប៉ុល លឹម | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. | ឯកឧត្តម អ៊ិត រ៉ាឌី | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. | ឯកឧត្តម តិច ច័ន្ទតារា | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៦. | ឯកឧត្តម ជេត ជាលី | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៧. | ឯកឧត្តម កត្តា អ៊ន | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៨. | ឯកឧត្តម ជិន ម៉ាលីន | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៩. | ឯកឧត្តម ផៃ ប៊ុនឈឿន | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១០. | ឯកឧត្តម ម៉ម វណ្ណៈ | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១. | ឯកឧត្តម ឌិត ទីណា | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១២. | ឯកឧត្តម គោស៊ុំ សារឿត | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣. | ឯកឧត្តម លឹម វ៉ាន់ | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤. | ឯកឧត្តម នូ សុវត្ថិ | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥. | ឯកឧត្តម ស៊ា ម៉ៅ | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១៦. | ឯកឧត្តម ពោង ឈង | មន្ត្រីជាន់ខ្ពស់ផ្នែករដ្ឋបាល និងជាប្រធានផ្នែកធនធានមនុស្ស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | សមាជិក |
| ១៧. | ឯកឧត្តម នាយឧត្តមសេនីយ៍ ឃុន វុធ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១៨. | លោកជំទាវ ឃុន រចនា | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៩. | ឯកឧត្តម កើត មៀច | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ២០. | ឯកឧត្តម សាន វិសាល | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២២. | ឯកឧត្តម មាស សុភ័ណ្ឌ | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ២៣. | ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់ | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ២៤. | ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៥. | ឯកឧត្តម អេ សុភា | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៦. | លោកជំទាវ ឡុង សុផល្លី | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ២៧. | ឯកឧត្តម ចាន់ វ៉ាស៊ី | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៨. | ឯកឧត្តម ចាន់ សុវឌ្ឍ | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៩. | ឯកឧត្តម សេង សុមុនី | អនុរដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា | សមាជិក |
| ៣០. | ឯកឧត្តម ស្រី សួន | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៣១. | ឯកឧត្តម អ៊ុច បូរ៉ា | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៣២. | លោកជំទាវ វង់ មយុរា | អនុរដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិកា |
| ៣៣. | ឯកឧត្តម ហោ សារុន | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៣៤. | ឯកឧត្តម ខៀវ តុលា | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៣៥. | ឯកឧត្តម កេង សុម៉ារតន៍ | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ៣៦. | ឯកឧត្តម គួច ចាន់នី | អគ្គនាយកបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

**ប្រការ២.**- ក្រុមការងារអន្តរក្រសួងខាងលើនេះមានភារកិច្ចដូចតទៅៈ

- ដឹកនាំធ្វើសេចក្តីព្រាងរបាយការណ៍ ស្តីពីការអនុវត្តសន្ធិសញ្ញា ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា សម្រាប់ ដាក់ជូនអង្គការសហប្រជាជាតិដែលមានជាអាទិ៍ របាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របាយការណ៍ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ របាយការណ៍ស្តីពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) និងរបាយការណ៍ផ្សេងៗទៀតដែលអង្គការសហប្រជាជាតិស្នើសុំ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច មុននឹងរៀបចំបញ្ជូនទៅអង្គការសហប្រជាជាតិ។
- ពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលកម្ពុជា លើសេចក្តីព្រាងរបាយការណ៍នានា របស់អង្គការសហប្រជាជាតិ ដូចជារបាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍របស់អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ រួមទាំងរបាយការណ៍របស់អ្នកតំណាងផ្សេងៗទៀត នៃអង្គភាពសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ដែលបានដាក់ជូនរាជរដ្ឋាភិបាល។
- បំពេញភារកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស តាមការចាត់តាំងរបស់រាជរដ្ឋាភិបាល។

**ប្រការ៣.**- ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាដើម្បីសម្រួលការងារ និងមានទីស្នាក់ការនៅគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

**ប្រការ៤.**- ក្រុមការងារអន្តរក្រសួងនេះ មានក្រុមការងារបច្ចេកទេសជាជំនួយ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម អ៊ិត រ៉ាឌី | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម តិច ច័ន្ទតារា | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. | លោកជំទាវ ហ៊ាន ប៉ូលីណេ | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៤. | ឯកឧត្តម កត្តា អ៊ិន | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៥. | ឯកឧត្តម នូ ស្ថាបត្យា | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៦. | ឯកឧត្តម ជីន ម៉ាលីន | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៧. | ឯកឧត្តម ខៀវ ពៅ | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម រុន គូ | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩. | ឯកឧត្តម ឡេង តុលា | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១០. | ឯកឧត្តម វ៉ាន់ ច័ន្ទតារា | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១១. | ឯកឧត្តម ឯម ច័ន្ទមករា | អគ្គលេខាធិការ ក្រុមប្រឹក្សជាតិសកម្មភាពជនពិការ | សមាជិក |
| ១២. | លោកជំទាវ ញ៉េប សុភាព | អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិកា |
| ១៣. | ឯកឧត្តម ជា ចាន់ទុំ | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ ក្រសួងផែនការ | សមាជិក |
| ១៤. | ឯកឧត្តម ចោង សុជាតិ | ប្រធានផ្នែកថវិកា និងហិរញ្ញវត្ថុភាគីជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | សមាជិក |
| ១៥. | ឯកឧត្តម ចាន់ វិចិត្រ | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១៦. | ឯកឧត្តម ម៉ែន អេង | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ១៧. លោកជំទាវ អ៊ុច និពន្ធ | អគ្គនាយករដ្ឋបាល និងបណ្ដឹង<br>គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ១៨. លោកជំទាវ ឆាំ ម៉ារី | អគ្គនាយកស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស<br>គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ១៩. ឯកឧត្តម ហេង សួរ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ<br>ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ២០. ឯកឧត្តម ពុត សាមិត្ត | អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ<br>ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២១. ឯកឧត្តម សួរ ឌីម៉ា | អនុប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ២២. ឯកឧត្តម ថៃ ផុន | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៣. ឯកឧត្តម ស៊ីង សុគង់ | អគ្គនាយកផែនការ និងគោលនយោបាយ<br>ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៤. ឯកឧត្តម ស៊ឹម សុខខេង | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៥. ឯកឧត្តម អ៊ិន ធឿន | អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការ<br>អន្តរជាតិ ក្រសួងទេសចរណ៍ | សមាជិក |
| ២៦. ឯកឧត្តម ស៊ាង ផល្លា | ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក នាង អេង | អគ្គនាយករង នៃអគ្គនាយកដ្ឋានយោធសេវា<br>ក្រសួងការពារជាតិ | សមាជិក |
| ២៨. លោក លឹម យូសូ | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ<br>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៩. លោក ម៉ែន សម្បត្តិ | អគ្គនាយករងអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ៣០. លោកវេជ្ជបណ្ឌិត លន់ ច័ន្ទរស្មី | អគ្គនាយករងបច្ចេកទេសសុខាភិបាល<br>ក្រសួងសុខាភិបាល | សមាជិក |
| ៣១. លោក ទូន សុផល | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣២. លោក សុខខេង នរិន្ទ | អគ្គនាយករង ក្រសួងបរិស្ថាន | សមាជិក |
| ៣៣. លោក ពៅ ពិសិដ្ឋ | អគ្គនាយករងព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ៣៤. លោក ឈី សុខា | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍<br>និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣៥. លោក ម៉ែន សម្បត្តិ | អគ្គនាយករងអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ៣៦. លោក ឡៅ សេរីវិសិទ្ធិ | អគ្គនាយករងនៃអគ្គនាយកដ្ឋានប្រេងកាត<br>ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣៧. លោក សាយ អំណាន | អគ្គនាយករងកិច្ចការសាសនា ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៣៨. លោក គី សុគន្ធ | អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | សមាជិក |
| ៣៩. លោក ជួរ ជេតទីវន្ត | អគ្គនាយករងកិច្ចការទូទៅ<br>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |

៤០. លោក ចាន់ រស្មី — អគ្គនាយករងរដ្ឋបាលកិច្ចការទូទៅ ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច — សមាជិក

៤១. លោក ឃ្លោក ដារ៉ា — ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ក្រសួងយុត្តិធម៌ — សមាជិក

៤២. លោក អេ ប៊ុនធឿន — ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក

៤៣. លោក ច័ន្ទ ប៉ុណ្ណិកា — អនុប្រធានរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក

៤៤. លោក ប៉ែន សុវណ្ណា — នាយការិយាល័យ ក្រសួងទេសចរណ៍ — សមាជិក

**ប្រការ៥.-** ក្រុមការងារបច្ចេកទេសខាងលើនេះ មានភារកិច្ចដូចតទៅ៖

- សិក្សា និងរៀបចំតាក់តែងសេចក្តីព្រាងរបាយការណ៍ ស្តីពីការអនុវត្តសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា សម្រាប់ដាក់ជូនអង្គការសហប្រជាជាតិដែលមានជាអាទិ៍ របាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របាយការណ៍ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ របាយការណ៍ស្តីពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) និងរបាយការណ៍ផ្សេងៗទៀតដែលអង្គការសហប្រជាជាតិស្នើសុំ ដើម្បីដាក់ជូនក្រុមការងារអន្តរក្រសួងពិនិត្យ និងសម្រេច។
- សិក្សា និងលើកអនុសាសន៍ជូនក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យ និងសម្រេច លើសេចក្តីព្រាងរបាយការណ៍នានារបស់អង្គការសហប្រជាជាតិ ដូចជារបាយការណ៍អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍របស់អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ រួមទាំងរបាយការណ៍របស់អ្នកតំណាងផ្សេងៗទៀត នៃអង្គភាពសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ដែលបានដាក់ជូនរាជរដ្ឋាភិបាល។
- បំពេញភារកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស តាមការកំណត់របស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ៦.-** ក្រុមការងារអន្តរក្រសួង និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិ មកចូលរួមផ្តល់យោបល់បន្ថែមលើការងារនេះ។

សមាជិកក្រុមការងារអន្តរក្រសួង និងសមាជិកក្រុមការងារបច្ចេកទេស មានសិទ្ធិរៀបចំក្រុមការងារ និងប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តភារកិច្ច ដូចមានចែងក្នុងប្រការ២ និងប្រការ៥ ខាងលើ។

សមាជិក នៃក្រុមការងាអន្តរក្រសួង និងក្រុមការងារបច្ចេកទេស អាចប្រើប្រាស់ថវិការបស់ស្ថាប័នសាមី ដើម្បីបំពេញបេសកកម្ម។

**ប្រការ៧.-** ការប្រព្រឹត្តទៅនៃក្រុមការងារទាំងពីរខាងលើនេះ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិការបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ក្រុមការងារទាំងពីរឱ្យមានប្រសិទ្ធភាព។

**ប្រការ៨.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៩.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធាន គ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានរាយនាមក្នុងប្រការ១ និងប្រការ៤ ខាងលើនេះ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១ កើត ខែបុស្ស ឆ្នាំ រកា ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ គ.ស.២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ដូចប្រការ១ និង ប្រការ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*